# របបកម្ពុជាប្រជាធិបតេយ្យ
# (1975-1979)

នៅថ្ងៃទី17 មេសា 1975 កងទ័ពខ្មែរក្រហមបានវាយរំដោះក្រុង ភ្នំពេញ និង ទីរួមខេត្តនានា។ ប្រជាជនក្រុង ភ្នំពេញ រីករាយអបអរសាទរនូវជ័យជំនះរបស់កងទ័ពខ្មែរក្រហមលើរបបសាធារណរដ្ឋខ្មែរ។ តែផ្ទុយទៅវិញ ពួកខ្មែរក្រហមបានគំរាមកំហែង និង បណ្តេញប្រជាជនឲ្យចេញពីក្រុងភ្នំពេញដោយបង្ខំ។

## ១. គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ

- ជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និង ទីប្រជុំជននានា
- លុបបំបាត់ទីផ្សារ និង រូបិយវត្ថុនានា
- កំទេចវត្តអារាម និង ផ្សឹកព្រះសង្ឃឲ្យទៅធ្វើស្រែចម្ការ
- បិទសាលារៀនទូទៅ និង គ្រឹះស្ថានសិក្សាគ្រប់ជាន់ថ្នាក់
- ប្រហារជីវិតបញ្ញាវន្ត មន្ត្រីរាជការក្នុងរបបចាស់ និង ប្រជាជនស្លូតត្រង់
- បង្កើតសហករកំរិតខ្ពស់ទូទាំងប្រទេស
- បណ្តេញប្រជាជនវៀតណាម និង ធ្វើ សង្គ្រាមជាមួយវៀតណាម
- ផ្តាច់មនោសញ្ចេតនាប្តី ប្រពន្ធ ឪពុកម្តាយ បងប្អូន និង គ្រួសារ

## ២. ការបែងចែកតំបន់រដ្ឋបាល

កម្ពុជាប្រជាធិបតេយ្យបានបែងចែកតំបន់រដ្ឋបាលនៃបរទេសកម្ពុជា ជាបីគឺ ភូមិភាគ តំបន់ និង សម្ហូភាពមូលដ្ឋាន។

- ភូមិភាគបូព៌ា: លេខាបក្សភូមិភាគលោក សោ ភឹម(សម្លាប់ឆ្នាំ 1978) មានខេត្តចំណុះ ស្វាយរៀង ព្រៃវែង កំពង់ចាមមួយផ្នែក និង ក្រចេះមួយផ្នែក ហើយចែកជាតំបន់ 21. 22. 23. និង 24។
- ភូមិភាគនារតី: លេខាបក្សភូមិភាគលោក ឈិត ជឿន ហៅ តាម៉ុក (ស្លាប់ឆ្នាំ 2006) មានខេត្តចំណុះ កណ្តាល តាកែវ កំពត និង កំពង់ស្ពឺមួយផ្នែក ហើយ ចែកជាតំបន់ 13. 25. 33. និង 35។
- ភូមិភាគបស្ចឹម: លេខាបក្សភូមិភាគលោក ជូ ជេត មានខេត្តចំណុះ កំពង់ស្ពឺមួយផ្នែក កំពង់ឆ្នាំង កំពង់សោម និង កោះកុង ហើយចែកជាតំបន់ 11. 15. 31. 32. និង 37។
- ភូមិភាគពាយ័ព្យ: លេខាបក្សភូមិភាគលោក ញឹម រស់ (សម្លាប់ឆ្នាំ 1978) មានខេត្តចំណុះ ពោធិ៍សាត់ និង បាត់ដំបង ហើយចែកជាតំបន់ 1. 2. 3. 4. 5. 6. និង 7។
- ភូមិភាគឧត្តរ: លេខាបក្សភូមិភាគលោក កុយ ធួន ហៅ ធុច(សម្លាប់ឆ្នាំ 1976) ដូរដាក់លោក កែ ពក ក្រោយមកដូរដាក់លោក កងចាប មានខេត្តចំណុះ កំពង់ធំ សៀមរាប និង ឧត្តរមានជ័យ ហើយចែកជាតំបន់ 41. 42 និង 43។
- ភូមិភាគឦសាន: លេខាបក្សភូមិភាគលោក ណៃ សារ៉ាន់ ហៅ យ៉ា(សម្លាប់ឆ្នាំ 1976) មានខេត្តចំណុះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែងមួយផ្នែក ក្រចេះមួយផ្នែក ចែកចេញជាតំបន់ 101. 102. 104. 105. 107. និង 505។

## ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និង បក្សកុំមុយនីសកម្ពុជា

៣.១ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ 1976-1978

- ខៀវ សំផន ជាប្រធានគណប្រធានរដ្ឋ ឬ ប្រមុខរដ្ឋ
- ប៉ុល ពត ជានាយករដ្ឋមន្ត្រី
- នួន ជា ជាប្រធានសភា តំណាងប្រជាជនកម្ពុជា
- អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី ក្រសួងការបរទេស
- វន វ៉េត ជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
- សុន សេន ជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ
- ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម។

៣.២ រចនាសម្ព័ន្ធមជ្ឈិមបក្ស កុំមុយនីសកម្ពុជា 1976-1978

- ប៉ុល ពត ជាលេខាបក្ស
- នួន ជា ជាអនុលេខាបក្ស
- សមាជិកបក្សមាន សោភឹម អៀងសារី សុនសេន ឈិតជឿន វនវ៉េត កែពក ញឹមរស់ ខៀវសំផន..។

## ៤. ជីវិតរស់នៅរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ពួកខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការពី 12-15ម៉ោង ក្នុងមួយថ្ងៃ អោយហូបតែបបរាវលាយត្រកួន ព្រលិត គល់ចេក គល់ល្ហុង។ គ្មានសំលៀកបំពាក់សមរម្យគ្មានជំរកគ្មានថ្នាំសង្កូវ និង បំបិទសិទ្ធសេរីភាពប្រជាជនទាំងអស់។ ប្រជាជនកម្ពុជាត្រូវរស់នៅរួមគ្នា ហូបរួមគ្នា និង ធ្វើការរួមគ្នា ដូចសម័យបុព្វកាល។

៤.១ វណ្ណៈសង្គម

ពួកខ្មែរក្រហមបានបង្កើតវណ្ណៈសង្គមនៅក្នុងការរស់នៅ:

- មូលដ្ឋានចាស់: ប្រជាជនពេញសិទ្ធ និង ប្រជាជនមិនពេញសិទ្ធ
- មូលដ្ឋានថ្មី: ប្រជាជនដែលទើប និង រំដោះចេញពីទីក្រុងភ្នំពេញជាពួបញ្ញើក្អែក ឬ ពួក 17 មេសា។ ពួកគេត្រូវពួកខ្មែរក្រហមប្រើឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរ បង្អត់អាហារ និង យកទៅសម្លាប់ចោលដោយគ្មានកំហុស។

៤.២ពិធីមង្គលការ

មង្គលការពួកខ្មែរក្រហមបានផ្សំផ្គុំពួកមូលដ្ឋានចាស់ដោយមូលដ្ឋានចាស់ រីឯមូលដ្ឋានថ្មី និង មូលដ្ឋានថ្មី មិនឲ្យកឡុំគ្នាបានឡើយ។ ពួកគេហៅឈ្មោះយុវជន យុវនារី ចាប់ដៃគ្នាពី 5 ទៅ 10 គូរ ពី 40 ទៅ 100គូរ ហើយប្តេជ្ញាចិត្តចំពោះមុខអង្គការ និង ទង់បក្ស។ ការរួចសម្រាកបានមួយថ្ងៃ រួចចូលធ្វើការបម្រើអង្គការវិញដោយរស់នៅបែកគ្នាតាមកងចល័តរាងៗខ្លួន រយះពេលមួយអាទិត្យ ឬ មួយ ខែ ជួបគ្នាម្តង។ ជនណាប្រកែកមិនព្រមទទួលយកការរៀបចំអោយមានគ្រួសារនេះចាត់ទុកជាខ្មាំងអង្គការ អង្គការ នឹង កំទេចចោល។

## ៥. ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

កត្តាសំខាន់ៗដែលបណ្តាលអោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមានបីគឺ កត្តាប្រជាជន កត្តាវិសុទ្ធកម្ម និង កត្តាសង្គ្រាមជាមួយវៀតណាម។